Derek Prince
MINISTRIES



ដំណោះស្រាយសម្រាប់ជំងឺដេកមិនលក់



(11)

នេះគឺជាពាក្យរបស់លោក ដេរក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> ខ្ញុំបានដេកលក់ទៅ ហើយក៏ភ្ញាក់ឡើងវិញ
> ដ្បិតព្រះយេហូវ៉ាទ្រង់ទប់ទល់ខ្ញុំ។
> ខ្ញុំមិនខ្លាចដល់មនុស្សទាំងសល់សែន
> ដែលបានតាំងខ្លួនព័ទ្ធជុំវិញទាស់នឹងខ្ញុំឡើយ។
> [ទំនុកតម្កើង ៣:៥-៦]

មានដំណោះស្រាយមួយសម្រាប់ជំងឺដេកមិនលក់។ ខ្ញុំចង់ដឹងថា
តើមានអ្នករាល់គ្នាប៉ុន្មាននាក់ដឹងថា ការតម្រូវគឺជាអ្វី
ក្នុងការមានការធានានៃភាពស្ងប់ស្ងាត់
ទទួលបានព្រះពរការនគងលក់រៀងរាល់យប់។

តើនរណាអាចរាប់មនុស្សរាប់លាននាក់ដែលមាននៅក្នុងសម័យបច្ចុប្បន្នរបស់យើងនេះ
ដែលត្រូវបានរងទុក្ខទារុណកម្មដោយការដេកមិនលក់
ឬដោយជំងឺដេកមិនលក់នោះ? ប៉ុន្តែមានបុរសម្នាក់
ដែលបានរកឃើញដំណោះស្រាយ។

> ខ្ញុំនឹងដេកលក់ទៅ ហើយក៏ភ្ញាក់ឡើងវិញ
> ដ្បិតព្រះយេហូវ៉ាទ្រង់ទប់ទល់ខ្ញុំ។

អ្នកប្រហែលជាគិតថាបុរសនោះមិនមានសម្ពាធដូចដែលអ្នកមាននោះទេ។ គាត់មិនត្រូវបានទទួលរងនូវទុក្ខលំបាកអ្វីទាំងអស់
គាត់មិនមានការព្រួយបារម្ភ និងការខ្វល់ខ្វាយអ្វីឡើយ។
ប៉ុន្តែអ្នកពិតជាយល់ខុសហើយ។

គាត់ប្រហែលជាមានសត្រូវយ៉ាងច្រើន សម្ពាធច្រើនជាង
ត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ច្រើនជាងពេលដែលអ្នកនៅរស់នៅក្នុងជីវិតរបស់អ្នកផ្ទាល់ទៅទៀត។

ប៉ុន្តែគាត់បានរកឃើញអាថ៌កំបាំង។ ខ្ញុំបានដេកលក់ទៅ។
ខ្ញុំក៏ភ្ញាក់ឡើងវិញ។ ខ្ញុំនឹងមិនភ័យខ្លាចអ្វីឡើយ។ ហេតុអ្វី?
ដោយសារតែព្រះអម្ចាស់ទប់ទល់ខ្ញុំ។
ជានរៀងរាល់យប់គាត់បានថ្វាយខ្លួនទៅព្រះអម្ចាស់
គាត់បានទុកចិត្តលើព្រះអម្ចាស់។
គាត់ដឹងថាព្រលឹងគាត់មានសុវត្ថិភាពដោយមានព្រះអម្ចាស់ថែរក្សាការពារ។ គាត់អាចដេកលក់ ហើយគាត់អាចភ្ញាក់ឡើងវិញបាន
ដោយគ្មានការថប់បារម្ភ ដោយគ្មានការភ័យខ្លាច
ដោយគ្មានការរងទុក្ខទារុណកម្មនៃការដេកមិនលក់ឡើយ។

ប្រសិនបើអ្នកមានបញ្ហាជាមួយការរងទុក្ខទារុណកម្មនៃការដេកមិនលក់ សូមចាំពាក្យរបស់ដាវីឌ ហើយអនុវត្តទៅ។

: WD-WFTW-011-KHM
: 24 Feb 2026
: derekprince.com/km/resources

